## មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ សេក សាំង ភេទប្រុស អាយុ៥៩ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ កងចល័ត**

**ស្រុកកំណើតនៅភូមិល្វា ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង**

**រស់នៅភូមិទួលពន្រ ឃុំទំនប់ដាច់ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:១២:៥២**

**២៩ទំព័រ**

ដានីៈ អីចឹងលោកពូដឹបូងខ្ញុំចង់ស្គាល់ឈ្មោះលោកពូពេញ ឈ្មោះសេក?

សាំងៈ សេក សាំង ។

ដានីៈ លោកពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

សាំងៈ ខ្ញុំអាយុនៅធ្វើការ៤៩ តែអាយុពិតខ្ញុំ៥៩នោះ ។

ដានីៈ អាយុពិត៥៩?

សាំងៈ បាទ!

ដានីៈ ម៉េចបានលោកពូដាក់អាយុតិចម៉្លេះ?

សាំងៈ ចេះរឿងមុនដំបូងដែលបន្ថយអាយុក្រោយពីសមាហរណកម្ម ការជ្រើសរើសស្មៀនដំបូងហើយនៅតំបន់នេះវាក្រមនុស្ស វាធនធានមនុស្សវាតិច អីចឹងអ្នកចេះត្រឹមខ្ញុំវាគ្រាន់បើជាងគេ ។ អីចឹងការជ្រើសរើសដំបូងហ្នឹងគឺអត់មនុស្ស នាំគ្នាធ្វើដើម្បីឲ្យបានដំណើរការការងាររដ្ឋបាល ហើយពេលនោះយកអាយុ៤០ ក្រោម៤០ ដល់ពេលហ្នឹងខ្ញុំវា៤០ទៅហើយ អីចឹងយើងបញ្ចុះអាយុមក បានធ្វើការងារហ្នឹង ។

ដានីៈ លោកពូកើតឆ្នាំមួយពាន់ប្រាំបួនប៉ុន្មានដែលទៅ?

សាំងៈ ៥៤ ។

ដានីៈ ហើយគ្រួសារលោកពូគាត់ឈ្មោះអីដែរ?

សាំងៈ គ្រួសារខ្ញុំឈ្មោះ គុយ រិទ្ធិ ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

សាំងៈ អាយុ៥៧ ។

ដានីៈ លោកពូមានកូនចៅប៉ុន្មាននាក់ដែរ?

សាំងៈ កូន៣ ។

ដានី៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

សាំង៖ ស្រី២ ប្រុស១ ។

ដានី៖ ធំៗអស់ហើយ?

សាំង៖ ការមានប្ដីប្រពន្ធអស់ហើយ ។

ដានី៖ បានរៀនសូត្រអីដល់ណាដែរ?

សាំង៖ រៀនបានតិចតួចសម័យនោះ វាមិនបានរៀនសូត្រអី ។

ដានី៖ គាត់កើតសង្គ្រាម?

សាំង៖ សមាហរណកម្មមកវាហួស ។

ដានី៖ ហើយលោកពូពីសមាហរណកម្មហើយលោកពូធ្វើស្មៀនរហូត ឬក៏យ៉ាងម៉េចដែរ?

សាំង៖ ដែលយើងធ្វើសមាហរណកម្មមកខាងកងទ័ពគេចាត់ចែងកិច្ចការងារ យើងធ្វើសមាហរណកម្មហើយខ្លះទៅនៅកងទ័ព ខ្ញុំគេឲ្យមកការងាររដ្ឋបាល យើងធ្វើការងារឃុំ ធ្វើជំនួយការពីដើមមិនឈ្មោះថាស្មៀនទេ ហៅថាជំនួយការឃុំធ្វើបាន១ឆ្នាំ វាភ្លេចទាំងខ្លួនឯង ដូចខ្ញុំនិយាយម៉ិញការជ្រើសស្មៀនក៏ជាប់ធ្វើស្មៀនជាប់មករហូត ។

ដានី៖ ពីឆ្នាំណាមក?

សាំង៖ ពីឆ្នាំ២០០២ ការជ្រើសរើសឆ្នាំ២០០២ មានការប្រកាសហ្នឹង២០០២ ។

ដានី៖ លោកពូអ្នកស្រុកកំណើតនៅណាដែរ? កំណើតកើតជាលោកពូ?

សាំង៖ ខ្ញុំនៅកំពង់ឆ្នាំង ។

ដានី៖ នៅភូមិអីដែរ នៅកំពង់ឆ្នាំង?

សាំង៖ នៅភូមិល្វា ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

ដានី៖ ហើយកាលពីក្មេងៗលោកពូរៀនដល់ណាដែរ?

សាំង៖ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៨ចាស់ ។

ដានី៖ រៀននៅ?

សាំង៖ រៀននៅសាលាស្វាយរំពារ ។

ដានី៖ យ៉ាងម៉េចបានជាលោកពូឈប់ត្រឹមថ្នាក់ទី៨ ឬមានព្រឹត្តិការណ៍អី?

សាំង៖ សម័យ៧០ កាលរដ្ឋប្រហារហ្នឹងក៏ខាងខ្ញុំទៅជាជាប់តំបន់រំដោះទៅ សង្គ្រាមដឹងហើយយើងអត់បានរៀនបន្តបួស ។

ដានី៖ លោកពូឈប់ឆ្នាំណាទៅ? ដែលលោកពូចូលបួស?

សាំង៖ កាលដែលប្រហែលជា ខ្ញុំអត់បានចាំប្រាកដទេ៧១ វាដាច់តំបន់រំដោះនិងតំបន់លន់ នល់រដ្ឋប្រហារទៅមានតំបន់២ ។

ដានី៖ ពីឆ្នាំ៧០ រដ្ឋប្រហារឆ្នាំ៧០?

សាំង៖ ៧០យើងនៅរៀនបានតិចតួចទេ ខ្ទង់៧១ហ្នឹង អីចឹងដាច់ការសិក្សាក៏បួស ។

ដានី៖ បួសបានប៉ុន្មានវស្សា?

សាំង៖ បួសតាំងពីហ្នឹងមក តាំងពី៧១-៧៥គេផ្សឹក ។

ដានី៖ បួសបានភឹកនឹងគេអត់?

សាំង៖ អត់បានបំពេញភឹកទេ បួសហ្នឹងនៅសាមណេររហូត៧៥ដាច់ភ្នំពេញ វាត្រូវបង្ខើយសង្ឃក៏គេផ្សឹក ។

ដានី៖ នៅវត្តស្វាយរំពារហ្នឹង?

សាំង៖ បាទ! នៅវត្តដដែល ។

ដានី៖ កាលហ្នឹងឪពុកម្តាយលោកពូគាត់ចង់ឲ្យបួស ឬលោកពូចង់បួសខ្លួនឯង?

សាំង៖ ការបួសសម័យហ្នឹងយើងគោរពឪពុកម្តាយ គាត់ឲ្យបួសៗ ។

ដានី៖ លោកពុកលោកពូគាត់ឈ្មោះអីដែរ?

សាំង៖ ពុកខ្ញុំឈ្មោះ សេក ចយ ។

ដានី៖ គាត់នៅរស់ ឬខូចហើយ?

សាំង៖ គាត់ខូចអស់ហើយ ទាំងម៉ែ ទាំងពុកខូចអស់ហើយ ។

ដានី៖ ម្តាយឈ្មោះអីដែរ?

សាំង៖ ជុក សៀប ។

ដានី៖ គាត់ខូចដែរ?

សាំង៖ ខូច ។

ដានី៖ បងប្អូនប៉ុន្មាននាក់ទៅ? បងប្អូនបង្កើត?

សាំង៖ ខ្ញុំទាល់តែរាប់៨ ។

ដានី៖ ៨ឬ៧?

សាំង៖ ៨នាក់ ។

ដានី៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ៨នាក់?

សាំង៖ ស្រី៤ ប្រុស៤ ។

ដានី៖ ស្មើរគ្នាល្អ លោកពូទីប៉ុន្មានទៅ?

សាំង៖ ខ្ញុំទី៣ ។

ដានី៖ ហើយអីចឹងដល់ពេលសឹកឆ្នាំ៧៥ហើយ លោកពូយ៉ាងម៉េចទៀតទៅ?

សាំង៖ ៧៥ធ្វើកងចល័ត គេឲ្យធ្វើកងចល័តលើកភ្លឺស្រែនៅមុំផ្លូវជាតិលេខ៥ ។

ដានី៖ ចេញពីកំណើត?

សាំង៖ នៅហ្នឹងគេបញ្ជូនកងចល័តវ័យកំលោះៗហ្នឹង ឲ្យទៅធ្វើកងចល័តឲ្យទៅលើកភ្លឺស្រែនៅអូរសណ្ដាន់មុំផ្លូវជាតិលេខ៥ អូរសណ្ដាន់, ជ្រៃបាក់ ។

ដានី៖ មកខាងទីរួមខេត្តវិញ?

សាំង៖ បាទ! តាមផ្លូវជាតិលេខ៥ហ្នឹង ។

ដានី៖ អាយុប៉ុន្មានដែលកាលហ្នឹងគេឲ្យទៅកងចល័ត?

សាំង៖ អត់បានចាំអាយុទេ នៅឆ្នាំ៧៥-៧៦ មិនបានចាំអាយុខ្លួនឯងមិនដឹងប៉ុន្មាន ។

ដានី៖ លោកពូធ្វើកងចល័តគេឲ្យរែកដី លើកអីហ្នឹងនៅតាមផ្លូវជាតិលេខ៥ហ្នឹងដល់ឆ្នាំណាទៅ?

សាំង៖ ដល់ឆ្នាំ៧៨ ។

ដានី៖ ដល់ឆ្នាំ៧៨ទៅណាទៀត?

សាំង៖ កាលនោះមានបញ្ហានៅព្រំដែនវៀតណាម ក៏គេតំរូវឲ្យទៅធ្វើកងទ័ព ។

ដានី៖ អីចឹងដល់ពេលយើងធ្វើកងចល័តរហូតដល់៧៨បានគេឲ្យទៅធ្វើកងទ័ព?

សាំង៖ បាទ! ទៅព្រំដែនវៀតណាម ។

ដានី៖ ខេត្តណាទៅ?

សាំង៖ ខ្ញុំទៅខាងកំពង់ចាមខាងកើត ទៅមេមត់ ។

ដានី៖ កាលហ្នឹងយ៉ាងម៉េចគេជ្រើសរើសឲ្យយើងចូល ឬលោកពូស្ម័គ្រចិត្ត?

សាំង៖ គេជ្រើសរើស ។

ដានី៖ ជ្រើសរើសបានន័យថាគេឲ្យលោកពូទៅមេមត់តែម្ដង ឬចូលកន្លែងណាហាត់រៀនហើយបានគេបញ្ជូន?

សាំង៖ ពួកខ្ញុំអត់មានហាត់ ជ្រើសរើសពីហ្នឹងទៅដេកភ្នំពេញបាន១យប់ បញ្ជូនទៅអត់ទាំងចេះបើកសោរកាំភ្លើងផង ។

ដានី៖ តែកាលហ្នឹងលោកពូមើលឆ្នាំ៧៥អាយុប៉ុន្មានទៅ?

សាំង៖ ខ្ញុំពី៧៥អាយុប្រហែល២០ឆ្នាំ ។

ដានី៖ ដល់៧៩បែប២៤-២៥?

សាំង៖ អត់ទាន់ដល់ទេ ព្រោះខ្ញុំមើល៨០-៨១ខ្ញុំអាយុម៉្លៃជាង ៨០-៨១ ។

ដានី៖ កាលហ្នឹងការជ្រើសរើសពីកងចល័ត ខាងណាជាអ្នកជ្រើសរើសពូឲ្យធ្វើកងទ័ព?

សាំង៖ មេស្មឹៗ កាលហ្នឹងខ្ញុំមិនដឹងមេតំបន់ គណៈតំបន់ ហើយកងទ័ពតំបន់អីខ្ញុំមិនស្គាល់គេទេ ។

ដានី៖ កាលហ្នឹងគេហៅតំបន់អីទៅនៅខាងកំពង់ឆ្នាំង?

សាំង៖ តំបន់៣១ ។

ដានី៖ មន្ទីរតំបន់គេនៅ?

សាំង៖ នៅខេត្តហ្នឹង ។

ដានី៖ កាលហ្នឹងខាងគណៈតំបន់គេជ្រើសរើស?

សាំង៖ គណៈការដ្ឋានកងចល័តគេប្រកាសប្រជុំ ប្រកាសជ្រើសរើសហ្នឹងក៏បានទៅ ។

ដានី៖ លោកពូដែលជួបគណៈតំបន់គេមកប្រជុំអត់?

សាំង៖ ខ្ញុំអត់ដឹងថាគណៈតំបន់ឈ្មោះអី ស្គាល់តែត្រឹមមេកងៗក្នុងកងចល័តហ្នឹង ។

ដានី៖ ខាងស្រុកគេស្គាល់ដែលអត់?

សាំង៖ ស្រុកខ្ញុំអត់បានទំនាក់ទំនងជាមួយស្រុកទេ ព្រោះខ្ញុំដាច់ពីស្រុកទៅនៅចល័តតំបន់ហ្នឹងតែម្តង គណៈតំបន់មិនដឹងពីណាមិនស្គាល់គេផង យើងស្គាល់តែមេកងវៀបជាកងៗ កងហា កងរយ កងវរៈខាងចល័ត ។

ដានី៖ ដល់ពេលលោកពូជ្រើសរើសទៅប៉ុន្មានពីខាងលោកពូទៅ?

សាំង៖ មួយកងរយបាន៣-៤នាក់ ហើយមនុស្សមួយតំបន់ហ្នឹងច្រើនណាស់ ។

ដានី៖ អីចឹងចេញពីតំបន់កំពង់ឆ្នាំងទៅភ្នំពេញច្រើន?

សាំង៖ ច្រើន ។

ដានី៖ ប្រហែលប៉ុន្មានទៅមួយជំនាន់ហ្នឹង?

សាំង៖ មិនបានស្គាល់គេទេ ស្រុកខុសៗគ្នា មិនដឹងប៉ុន្មានអីប៉ុន្មានទេ ដឹងតែខ្លួនឯង ។

ដានី៖ លោកពូកាលហ្នឹងដូចស្រុកគេហៅស្រុករលាប្អៀរ, ស្រុកទឹកផុស គេហៅអីចឹងឬគេហៅជាលេខ?

សាំង៖ ហៅជាលេខ ។

ដានី៖ ស្រុកលេខប៉ុន្មានកាលទៅខាង?

សាំង៖ ចាំមើលខ្ញុំចាំវាមិនអស់ទេ មានស្រុក១២, ១៤ ស្រុក១០ វាភ្លេចស្រុកឯងទៀតកំពង់លែងស្រុកលេខប៉ុន្មានទេ ។ មើល១២ កំពង់ត្រឡាច, ១៤ ទឹកផុស, ១០ ស្រុកបរិបូរណ៍, ស្រុក១៦ កំពង់លែង, ស្រុក២០ រលាប្អៀរ, ស្រុក១៨ កំពង់ត្រឡាចក្រោម ណាណីភ្លេចអស់ ។

ដានី: មានស្រុក១០, ស្រុក១២, ស្រុក១៤, ស្រុក១៦, ស្រុក១៨, ស្រុក២០?

សាំង: អីចឹងឯង ។

ដានី: គេអត់ដាក់លេខសេស គេដាក់លេខគូរទាំងអស់?

សាំង: មិនដឹងម៉េចគេហៅតែអីចឹង ។

ដានី: កាលហ្នឹងគណៈតំបន់លោកពូអត់ស្គាល់ឈ្មោះគាត់ទេ?

សាំង: អត់ទេ មិនដឹងតំបន់ឈ្មោះអី វាស្គាល់តែមេវរៈរបស់ខ្លួនឯង វរៈកងចល័ត កងវរយ កងហា ។

ដានី: គេជ្រើសរើសមួយតំបន់ទៅ ដែលបញ្ជូនទៅភ្នំពេញហ្នឹងប្រហែលប៉ុន្មាននាក់ទៅពីតំបន់យើង ៣១?

សាំង: ខ្ញុំអត់ដឹងទេ អត់ដឹងថាប៉ុន្មានទេ ។

ដានី: ទៅសំរាកនៅភ្នំពេញ១យប់?

សាំង: ប៉ុន្តែខ្ញុំដឹងតែចេះ ជ្រើសរើសកងចល័តមួយកងដែលដាក់ពួកខ្ញុំ១២០នាក់ហ្នឹងទៅរៀបមួយកង១២០ រៀបកងវរយ គេហៅកងវរយ តែនៅគ្រប់ស្រុក ចូលច្របូកគ្នា ។

ដានី: អីចឹងពេលដែលលោកពូទៅដល់ភ្នំពេញ ហើយបញ្ជូនទៅមេមត់ហ្នឹង នៅក្នុងកងពលលេខប៉ុន្មានទៅ?

សាំង: ខ្ញុំអត់ដឹងថាកងពលលេខប៉ុន្មានទេ ទៅដល់កន្លែងគេបញ្ចូលបានស្គាល់ គេហៅកងពល៦០៣

ដានី: ដល់ពេលលោកពូចូលទៅដល់កន្លែងកំពង់ចាម ដល់ខាងមេមត់ បានដឹងថាកងពល៦០៣?

សាំង: បាទ!

ដានី: ហើយកងពល៦០៣ដែលយើងធ្វើប្រតិបត្តិការ ដែលយើងប្រចាំនៅខ្សែត្រៀមនៅស្រុកមេមត់ ហើយនៅស្រុកណាទៀតទៅ?

សាំង: ខ្ញុំវាអត់ដឹងព្រំប្រទល់ស្រុកណា ត្រឹមណាទេ តែទៅម្តុំហ្នឹងសុទ្ធតែស្រុកមេមត់ហ្នឹងតែម្តង ។

ដានី: ផ្លូវជាតិលេខ៧ ឬយ៉ាងម៉េច?

សាំង: ផ្លូវជាតិលេខ៧ ។

ដានី: លោកពូនៅក្នុងវរសេនាតូច, វរសេនាធំលេខប៉ុន្មានទៅ?

សាំង: ខ្ញុំអត់មានវរសេនាធំទេ ខ្ញុំនៅតែក្នុងវរសេនាតូច ទល់តែយូរបានយើងដឹងថា ព្រោះយើងអត់ដែលធ្វើទ័ពនឹងគេ នៅតែទាហានព្រះសង្ឃ ដល់គេដាក់ធ្វើទ័ពមិនដឹងអ្នកណាធំ អ្នកណាតូច ខ្ញុំអត់ទេ អត់ចាប់អារម្មណ៍ នៅក្នុងវរសេនាតូចលេខ៦៣ ។

ដានី: វរសេនាតូច៦៣ហ្នឹង ជាវរសេនាតូចឯករាជ្យឬចំណុះឲ្យវរសេនាធំណា?

សាំង៖ អត់ដឹងថានៅវរសេនាតូចណា វរសេនាធំណាទេ ដឹងតែខ្ទង់៦៣ៗ មេវរៈឈ្មោះវ៉ាន ។

ដានី៖ គាត់នៅដែលអត់សព្វថ្ងៃ?

សាំង៖ មិនដឹងទៅណាឥឡូវ អត់ដឹងដែរ ។

ដានី៖ ហ្នឹងវរសេនាតូច៦៣?

សាំង៖ បាទ!

ដានី៖ វរសេនាធំអត់ដឹងលេខប៉ុន្មាន?

សាំង៖ អត់មានដឹងវរសេនាធំណាផងខ្ញុំ ។

ដានី៖ ក្រោយមកលោកពូមានដឹងនៅក្នុងកងពល៦០៣ហ្នឹង មានប៉ុន្មានវរៈទៅ?

សាំង៖ អត់ដឹងទេ អត់ដឹងថាមានប៉ុន្មានវរៈទេ ព្រោះនៅក្នុងកងពល៦០៣រយៈពេលខ្លីពេក តែ ៧៨-៧៩ហ្នឹងដាច់ហ្នឹងរប៉ាត់រប៉ាយលែងនៅជាមួយគ្នាទៅ ។

ដានី៖ ទៅហ្នឹង៧៨ ខែប៉ុន្មានទៅដែលលោកពូទៅដល់?

សាំង៖ ៧៨ខែច្រូតហើយ ប្រហែលជាខែប៉ុន្មានទេ ខែយើងច្រូត ។

ដានី៖ ច្រូតស្រូវវាមានពីខែ១០, ១១ ចាប់ផ្ដើមច្រូត ។

សាំង៖ នៅតំបន់យើងមិនមែនខែ១០, ខែ១១ទេ នៅនោះច្រើនច្រូតខែ១-២ ។

ដានី៖ អីចឹងតាំងពីដើមឆ្នាំ៧៨?

សាំង៖ តាំងពីដែលថាវៀតណាមវៃចូលជិតដល់កំពង់ចាម ជិតដល់ទន្លេបិទតាំងពីខែហ្នឹងមក មកដល់ហ្នឹងវៃយួនតាំងពីកណ្ដាលជ្រុំដេញអីចឹងទៅ ។

ដានី៖ ដេញទៅមួយសារ?

សាំង៖ ដេញទៅមួយសារ តែកាលទៅវៃជាមួយយួនបានតែកន្លះខែ ទៅដល់គេបញ្ចូលមិនដឹងណាណី មនុស្សមិនធ្លាប់ធ្វើសង្គ្រាម ។

ដានី៖ មេកងពលពីណាគេ?

សាំង៖ មេកងពលអត់ស្គាល់នាមត្រកូលគាត់ទេ ឈ្មោះតាវិន ។

ដានី៖ តាវិន មេកងពល អនុគាត់?

សាំង៖ អត់ដឹង ខ្ញុំអត់ស្គាល់ មិនដឹងអនុពីណា ឃើញតែមេកងពលតែមួយហ្នឹង ។

ដានី៖ តាវិន ហ្នឹងគាត់កូនប្រសារតាម៉ុក ហ្នឹង?

សាំង៖ តាមដឹងថាកូនប្រសារតាម៉ុក ព្រោះនៅរយៈពេលខ្លីពេកមិនដឹងណាណី ។

ដានី៖ រាងគាត់យ៉ាងម៉េចតាវិន?

សាំង៖ រាងល្អិត ។

ដានី៖ ខ្មៅឬស?

សាំង៖ មិនខ្មៅទេ គាត់រាងជ្រះដែរ ។

ដានី៖ សំដីសំដៅយ៉ាងម៉េច ដូចអ្នកមកពីខាងណា?

សាំង៖ មកពីខាងតាម៉ុកអី ខ្ញុំមិនដឹងថាទឹកន្លែងកំណើតគាត់ស្អីណា ខ្ញុំអត់ដឹងដែរ ។

ដានី៖ តែគេហៅគាត់តារិន?

សាំង៖ បាទ!

ដានី៖ ប្រពន្ធគាត់មានដែលទៅជាមួយទេ?

សាំង៖ អត់ទេ ខ្ញុំមិនដែលស្គាល់ផង លឺតែឈ្មោះ ។

ដានី៖ លឺតែឈ្មោះតារិន?

សាំង៖ អត់ទេ ខ្ញុំស្គាល់តារិន តែប្រពន្ធខ្ញុំលឺតែឈ្មោះ ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអី?

សាំង៖ ឈ្មោះយាយហូ ។

ដានី៖ តារិន គាត់រាងល្អិត រាងសដែរ?

សាំង៖ បាទ!

ដានី៖ កាចឬស្លូតតារិន?

សាំង៖ វាលំបាកនឹងថាកាចឬស្លូត ព្រោះថាយើងមិនបាននៅជាមួយគាត់ដឹងចរិតយ៉ាងណា ព្រោះនៅតែពីចំងាយ ។

ដានី៖ ចុះលោកពូស្គាល់តាបាវ ទេ? តាបាវ អន្ទង់វែង ។

សាំង៖ តាបាវ ណា ។

ដានី៖ គាត់ឈ្មោះ ណុប សុជាតិ ហៅបាវ ។

សាំង៖ អត់ ។

ដានី៖ ចុះតាម៉ុន?

សាំង៖ តាម៉ុន?

ដានី៖ បាទ!

សាំង៖ មិនដឹងតាម៉ុន ណា ។

ដានី៖ អត់អីទេ ។ អីចឹងលោកពូថាគេបញ្ជូនពីភ្នំពេញទៅដល់មេមត់ហ្នឹងយើងរៃបានតែមួយរយៈខ្លីទេឃួនចូលមក?

សាំងៈ បាទ! រយៈខ្លី យួនចូលមកទាំងស្រុង រប៉ាត់រប៉ាយខ្ញុំលែងនៅហ្នឹង ទៅជាមករប៉ាត់របាយក្នុងព្រៃជាប់ជាមួយ៨០១នេះមក ។

ដានីៈ រប៉ាត់របាយពីត្រឹមណាមកលោកពូ ដែលលោកពូទៅដំបូងយើងនៅ៦០៣ ដល់ពេលទៅមួយភ្លែតវៃយួនបុកចូលមកយើងបាក់ យើងបែកខ្ចាត់ខ្ចាយទៅចូលជាមួយ៨០១ពីឆ្នាំណា?

សាំងៈ ខ្ញុំ៨០១ហ្នឹង ខ្ញុំមកជួប៨០១ជួបបងនៅភូមិជាមួយគ្នា មកនៅលើហៅ៨១ នៅលើភ្នំផ្លូវទន្លេល្ពៅនៅមុំ៣ ។

ដានីៈ ឆ្នាំណាលោកពូចូល៨០១?

សាំងៈ ប្រហែលជាឆ្នាំ៨១ ។

ដានីៈ ហ្នឹងចូលនៅទន្លេល្ពៅ?

សាំងៈ កាលដែលមកវារប៉ាត់របាយពីនោះមកចេះតែទីណាត់ទីណែងរុកព្រៃ រុកផ្សែមកហ្នឹង ។

ដានីៈ ដាច់មេ ដាច់កើយ?

សាំងៈ ដាច់មេ ដាច់កើយនៅជាក្រុមៗហ្នឹងមិនដឹងទៅណា ចេះតែទីណាត់ទីណែងមក ក៏មកជួបបងនៅភូមិជាមួយខ្ញុំ ក៏នៅជាមួយគាត់ហ្នឹងទៅ៨០១ នៅទន្លេល្ពៅ ។

ដានីៈ ជួបពីណាគេ?

សាំងៈ គាត់ស្លាប់បាត់ហើយ ។

ដានីៈ បងណា?

សាំងៈ បងភាព ។

ដានីៈ ហើយបងភាព គាត់នៅក្នុង៨០១ដែរ តួនាទីគាត់ធ្វើអីដែរ?

សាំងៈ កងរយកាលនោះ គេហៅកងធំៗ ។

ដានីៈ ចុះលោកពូកងពល៦០៣ ដល់ពេលបែកបាក់គ្នា ក្រោយមកកងពល៦០៣ហ្នឹងមានដដែលឬមានបែកបាក់គ្នាយ៉ាងម៉េចខ្លះទៀត?

សាំងៈ អត់ទេ តាំងពីបែកបាក់គ្នាហ្នឹង អត់មានទៀតចប់បាត់អត់មាន៦០៣ទៀតទេ ។

ដានីៈ ចប់តាំងពីឆ្នាំណាទៅ បើតាមលោកពូដឹង?

សាំងៈ តាំងពីខ្ញុំបែកមក ដល់ខ្ញុំមកនៅ៨០១អត់មាន៦០៣ អស់៦០៣ ។

ដានីៈ អីចឹងតាំងពីឆ្នាំ៨១មកលែងមានហើយ? លែងឃើញ?

សាំងៈ លែងមាន អត់ឃើញមាន៦០៣ ។

ដានីៈ ហើយតាវិន យ៉ាងម៉េចទៅ?

| | |
|---|---|
| សាំង: | តាវិន ដែលខ្ញុំបែកក្រោយមកលឺថាស្លាប់បាក់បែកគ្នាម៉េចទេ មិនដឹងស្អីទេរឿងរ៉ាវ ។ |
| ដានី: | ស្លាប់មុនឆ្នាំ៨១ ឬក្រោយ៨១? |
| សាំង: | ខ្ញុំអត់ចាំឆ្នាំទេកាលដែលគាត់ស្លាប់ ។ |
| ដានី: | តែលោកពូមានលឺដំណឹងថាដល់ពេលលោកពូមកចូល៨០១ គាត់ស្លាប់ហើយ ឬក៏មិនទាន់ទេ? |
| សាំង: | ខ្ញុំចូល៨០១បានដឹងដំណឹងថាគាត់ស្លាប់ ជួបគ្នាគ្នីនិយាយរឿងគាត់ស្លាប់ហ្នឹង ។ |
| ដានី: | គេនិយាយថាម៉េច? គាត់ស្លាប់ដោយសារមូលហេតុអី? |
| សាំង: | ស្លាប់ដោយសារថាតាម៉ុក បាញ់ចោលយ៉ាងម៉េចទេ ខ្ញុំមិនបានចាប់អារម្មណ៍ថាយ៉ាងណា ។ |
| ដានី: | ខ្ញុំលឺអីចឹងដែរ លឺថាតាម៉ុក បាញ់គាត់ចោល ។ |
| សាំង: | បើលឺថាអីចឹង លឺថាឪពុកក្មេកបាញ់កូនប្រសារចោល ដូចថាកូនប្រសារក្បត់ ។ |
| ដានី: | ថាគាត់នាំនារីៗយកទៅលក់ឲ្យថៃ អីចឹងមែនឬយ៉ាងម៉េច? |
| សាំង: | មិនដឹងម៉េច មិនដឹងដែរ ។ |
| ដានី: | ហ្នឹងបាត់តាំងពី៨១ តាំងពីដំបូងៗ ពីរត់មកឈូនចូលមក រត់មកភ្លាមៗតាម៉ុក បាញ់ចោលពេលហ្នឹង ឬយូរដែរ? |
| សាំង: | មិនដឹងពេលណាទេ ខ្ញុំបែកបាក់គ្នាទៅ ។ |
| ដានី: | ហើយចុះយ៉ាងម៉េចបានលោកពូទៅដល់ខាងទន្លេល្ពៅវិញ? ដំបូងបំផុតដែលលោកពូរត់មកយើងទៅដល់ទន្លេល្ពៅមុនគេ ឬក៏ទៅដល់កន្លែងណា? |
| សាំង: | វាច្រើនដំណាក់ណាស់ កាលដែលរត់ជួបគ្នានៅនឹងព្រៃ គេត្រូវបញ្ជូនកំលាំងហ្នឹងឡើងមកភ្នំដើម្បីមករកបង្អែក មកនៅនឹងដីថៃហ្នឹង ខ្ញុំឡើងមកហ្នឹង ។ |
| ដានី: | អីចឹងយើងមកដល់ជង់រែកដំបូងគឺនៅទន្លេល្ពៅទេ? |
| សាំង: | បាទ! ទន្លេល្ពៅ ។ |
| ដានី: | មិនមែនមកដល់៨០៨ទេ? |
| សាំង: | នៅមុំ៣ ។ |
| ដានី: | ដំបូងបំផុតមកដល់មុំ៣? |
| សាំង: | បាទ! |
| ដានី: | ហើយពេលដែលលោកពូមកដល់មុំ៣ លោកពូចូលជាមួយកងពល៨០១? |
| សាំង: | ៨០១ជួបបងដែលខ្ញុំនិយាយម៉ិញហ្នឹងគាត់នៅ ។ |

ដានី: មកដល់កន្លែងមុំ៣ កន្លែងលើដែនទី កន្លែងនេះព្រំប្រទល់ខ្មែរយើង ថៃ ហើយនិងឡាវ ពើយហ្នឹងមុំ៣នៅកន្លែងហ្នឹងតែម្តង?

សាំង: មុំ៣ខ្ញុំមើលដែនទីខ្ញុំមិនយល់ទេ ខ្ញុំមិនចេះ មិនដឹងគេអាពើយណា តែទីតាំងនៅទន្លេល្ពៅ ហ្នឹងតាមពើយមាត់ភ្នំ ។

ដានី: នៅទន្លេល្ពៅគ្នាច្រើនទៅនៅហ្នឹងដំបូង?

សាំង: នៅមនុស្សច្រើនមួយកងពល៨០១ហ្នឹង ។

ដានី: កងពលផ្សេងៗទៀត?

សាំង: ព្រោះនៅហ្នឹងមានមេ០៥ គាត់៨០១ ។

ដានី: តា០៥ ៨០១?

សាំង: បាទ!

ដានី: កងពលផ្សេងទៀតមាននៅហ្នឹងអត់?

សាំង: នៅហ្នឹងមានកងពលភូមិភាគកណ្តាល កងពល៨០១ កងពល៩២០ នៅតំបន់ទន្លេល្ពៅ ហ្នឹង ។

ដានី: មាន៣ហ្នឹងនៅដំបូង?

សាំង: មិនដឹងអ្នកណាទៀត តែកន្លែងធំៗមាន ៩២០, ភូមិភាគកណ្តាលមានតាពក ។

ដានី: តាពក កងពលលេខប៉ុន្មាន?

សាំង: កាលនោះមិនដឹងលេខប៉ុន្មាន ខ្ញុំហៅភូមិភាគកណ្តាល ។

ដានី: ដល់ពេល៩២០?

សាំង: គេហៅ៩២០ ចេះតែហៅតាមគេ ។

ដានី: ភូមិភាគកណ្តាលរបស់តាពក, ៩២០របស់ពីណាគេ?

សាំង: ៩២០របស់មេ របស់តាសាន ខ្ញុំមិនសូវចាំមេ ចាំកើយ ។

ដានី: ហើយដល់ពេលលោកពូចូល៨០១ហើយ លោកពូនៅទន្លេល្ពៅទៀត ឬចូលមកខាងក្នុង វិញ?

សាំង: ខ្ញុំតាំងពីឡើងទៅលើភ្នំហ្នឹង ខ្ញុំអត់ដែលបានចុះមកដីខ្មែរ ។

ដានី: ម៉េចអីចឹង?

សាំង: ខ្ញុំនៅជួនកាលគេឲ្យបង្រៀនក្មេង មាននៅមូលដ្ឋានខាងក្រោយ ។

ដានី: អីចឹងពេលដែលលោកពូចូលទៅដល់៨០១ លោកពូធ្វើផ្នែកខាងអី?

សាំង: ខ្ញុំនៅមើលប្រពន្ធៗគេនៅក្រោយ គេហៅមូលដ្ឋានខាងក្រោយ គេមកមុខគេចាត់តាំងឲ្យខ្ញុំនៅមើលកូនចៅ ប្រពន្ធកូនគេ ។

ដានី: ខាងក្រោយនៅទន្លេល្ពៅកាលហ្នឹងគេហៅអី?

សាំង: ទន្លេល្ពៅ ។

ដានី: ខាងក្រោយលោកពូនៅភូមិ ឬគេហៅយ៉ាងម៉េច?

សាំង: អត់ភូមិគេ នៅក្នុងអគ្គភាព នៅក្នុងកន្លែងកងដឹកជញ្ជូន មាននារី តែខ្ញុំនៅខាងពួៗកងទ័ពគេឲ្យនៅមើលប្រពន្ធៗគេ ខាងក្រោយ គេហៅនៅក្រោយ ។

ដានី: គ្នាច្រើនទេកាលហ្នឹង?

សាំង: មួយកងរយមើលតែមួយកងខ្ញុំ ។

ដានី: មើលតែមួយកងរយ មិនមែនមើលមួយកងពលទេ?

សាំង: មិនមែនទេ មួយកងខ្ញុំគេឲ្យមើលអីចឹង ហើយកងគេមានអ្នកមើលកូនចៅគេ មើលថែយប់ព្រលប់កូនឈឺ កូនគ្រុន ។

ដានី: បើសិនមួយកងពលតែម្តងពីណាអ្នកមើល? ដូចថាមើលខាងសមរភូមិខាងក្រោយ?

សាំង: មួយកងពលឲ្យប្រពន្ធគាត់ មីងណន នៅមើលគ្រប់គ្រងនេះខាងក្រោយ ។

ដានី: ហើយលោកពូមើលតែនេះទេ?

សាំង: ខ្ញុំមើលតែមួយកង ។

ដានី: កាលហ្នឹងម៉េចលោកពូនៅខាងក្រោយ? មានរបួស ពិការ ឬអត់ទេ?

សាំង: អត់មាន តែបងដែលនៅគាត់ឲ្យនៅ ។

ដានី: ឈ្មោះភាព?

សាំង: បាទ!

ដានី: អីចឹងលោកពូអត់បានចុះមកធ្វើសកម្មភាពអីខាងក្នុង?

សាំង: ខ្ញុំនិយាយរឿងបាញ់កាំភ្លើងខ្ញុំអត់ចេះបាញ់ឲ្យត្រូវ អត់ចេះបាញ់ទេកាំភ្លើង ទល់សព្វថ្ងៃហ្នឹងខ្ញុំអត់ចេះបាញ់ ចេះតែកេះកៃប៉ុន្តែឲ្យបាញ់តំរង់ទៅរកអីៗអត់ដឹងទេ ។

ដានី: លោកពូដូចថាស្មារតីយើងតិចឬយ៉ាងម៉េច?

សាំង: ស្មារតីតិចតែម្តង រឿងខ្លាច រឿងភ័យ ។ ទៅកាលយើងទៅវៃមុនដំបូង ទៅវៃយួនមុនដំបូង ទៅបានកន្ទះខែហ្នឹងខ្ញុំបាញ់គ្រាប់អស់ប្រហែលមួយបង់ ខ្ញុំលិបតែក្នុងត្រង់សេមិនបានច្បាំងនឹងគេទេ ។

ដានី: ចុះគេមានថាឲ្យ ឬក៏គេរិះគន់អីដែលអត់?

សាំង:	នៅក្នុងត្រង់សេ មិនដឹងអ្នកណារិះគន់ថាម៉េចផង ។

ដានី:	ថាយើងអត់ដាច់ខាត?

សាំង:	អត់ទេ មិនដែលគេថា ថ្ងៃនោះវៃទៅមានអ្នករបួសខ្ញុំនិយាយប្រវត្តិ មានអ្នករបួសខ្ញុំក៏លី អ្នករបួសរត់ចេញមកក្រៅ រត់ខ្ញុំមករហូតជាមួយវា ដេកពេទ្យនៅណាអត់ស្គាល់ ។

ដានី:	ដេកពេទ្យនៅណា?

សាំង:	ដេកពេទ្យនៅហ្នឹង អីខាងកើតហ្នឹង ។

ដានី:	ខាងមុំ៣ហ្នឹង?

សាំង:	អត់ទេ កាល៧៨មុន៧៩ ។

ដានី:	ពេទ្យខាងស្ទួង ខាងកណ្ដុរជ្រុំ?

សាំង:	បាទ! នៅខាងហ្នឹងឯងតែមិនដឹងត្រង់ណា ដេកពេទ្យហ្នឹងមកទាល់តែអ្នករបួសគេយកទៅភ្នំពេញ ខ្ញុំចេះតែនៅពេទ្យ កាលហ្នឹងចេះសំណាងគ្មានអ្នកណាគេតាម បើតាមគេវៃយើងចោល ។

ដានី:	ដូចថាយើងចេះតែគេច?

សាំង:	ខ្ញុំនិយាយត្រង់ខ្ញុំគេចៗកាលច្បាំងខ្ញុំមិនចូលចិត្តទេ ខ្ញុំខ្លាច ។

ដានី:	សំណាងដែលលោកពូដល់ពេលយើងនៅ៨១នៅខាងក្រោយ?

សាំង:	ខាងក្រោយរហូត ដល់ទៅចប់ចុះ យើងចុះមកដីខ្មែរហើយក្រោយពីចរចារអ៊ុនតាក់នាយអាយបានមកនៅដីខ្មែរវិញខ្ញុំនៅបង្ហាត់តែក្មេងទេ គេឲ្យនៅបង្ហាត់កូនក្មេង បង្រៀនអក្សរឯងគ្រាន់បើជាងគេ និយាយរឿងអក្សរសាស្ត្រ ។

ដានី:	ចុះលោកពូពេលដែលយើងនៅកន្លែងទន្លេល្អៅមាន៣កងពល មានអ្នកក្តាប់រួមដែលអត់ទេ? ដូចថាក្តាប់ខាងក្រោយ?

សាំង:	នៅហ្នឹងមុខសញ្ញាតាសុន សេន នៅគ្រប់គ្រងមួយមុខសញ្ញា តាសុន សេន ។

ដានី:	ចុះបន្ទាប់ពីតាសុន សេន?

សាំង:	មិនដឹងទេ មិនដឹងពីណាអនុ ពីណាសមាជិក ។

ដានី:	អត់ដឹងទេ?

សាំង:	អត់ដឹងទេ ។

ដានី:	គ្រប់គ្រងខាងប្រជាជន?

សាំង:	វាអត់មានប្រជាជនទេ សុទ្ធតែប្រពន្ធ សុទ្ធតែកងទ័ព ។

ដានី:	គ្រួសារទ័ព?

សាំង:	គ្រួសារទ័ពគេឲ្យមើលតាមក្រុមៗ តាមកង ដូចជា៨០១មានមីងណន គាត់មើលខាងក្រោយទៅរាយការណ៍ទៅ ។

ដានី:	ចុះខាងកណ្ដាល?

សាំង:	ខាងកណ្ដាលខ្ញុំអត់ដឹងទេ ។

ដានី:	ខាង៩៧០?

សាំង:	ក៏អត់ដឹងដែរ ។

ដានី:	ចុះខាងកងទ័ពគេចុះមកធ្វើការនៅខាងណា៨០១?

សាំង:	គេធ្វើតាមអ្នកដែលឡើងចុះជិតដល់ភ្នំពេញ ឡើងចុះ ។

ដានី:	ធ្វើបានឆ្ងាយ?

សាំង:	បាទ! អ្នកធ្វើដល់មុខកំពូល ។

ដានី:	ដល់មុខកំពូល ដល់ភ្នំពេញ?

សាំង:	គេអ្នកឡើងចុះទៅ ។

ដានី:	ចុះមន្ទីរពេទ្យនៅខាងទន្លេល្អោមានមន្ទីរពេទ្យគេដែលអត់?

សាំង:	មាន ។

ដានី:	មន្ទីរពេទ្យនៅម្ដុំណា?

សាំង:	នៅទៅក្រោយអីឃ្វាំង ចូលទៅក្នុងដីថៃ ។

ដានី:	ចូលទៅដីថៃ?

សាំង:	អេ៎! មិនមែនដីថៃទេ ដីយើងតែចូលទៅជ្រៅ ។

ដានី:	គេមើលមានអ្នកជំងឺទៅមើលច្រើន?

សាំង:	មាន កូនចៅ ប្រពន្ធកូន ឈឺគ្រុន ធម្មតារបួស ។

ដានី:	មានបុគ្គលិកពេទ្យច្រើនដែរ?

សាំង:	មានបុគ្គលិកមាន គេបង្រៀនពេទ្យត្រឹមត្រូវ ។

ដានី:	រៀនមកពីណាទៅពេទ្យ?

សាំង:	អត់ដឹងទេ រៀនតាមអគ្គភាពគេ ។

ដានី:	ពីណាគេអ្នកគ្រប់គ្រងនៅពេទ្យ?

សាំង:	តាមដែលយើងដឹងពេទ្យលន ។

ដានី:	គាត់នៅណាសព្វថ្ងៃពេទ្យលន?

សាំង:	អត់ដឹងទេ មិនដឹងទៅណាមកណា ។

ដានី:	បែកគ្នាតាំងពីពេលណាទៅ?

សារ៉ាំង:	បែកគ្នាដែលយើងចុះមកដីខ្មែរ កាលយើងនៅលើភ្នំគ្រាន់តែថាហ៎ចុះមកដីខ្មែរ ពួកខ្ញុំមកនេះ ពេទ្យគេមិនដឹងទៅណា មកណា អត់ដឹងដែរ បែកបាក់ៗ

ដានី:	នៅខាងទន្លេល្ពៅហ្នឹងយើងផ្លាស់ចេញឆ្នាំណាទៅ? យើងចេញពីទន្លេល្ពៅ?

សារ៉ាំង:	ចេញពីទន្លេល្ពៅឆ្នាំគេវ៉ៃរត់ខ្ចាត់ខ្ចាយហ្នឹងឯង មិនដឹងឆ្នាំប៉ុន្មានទេខ្ញុំអត់ចាំទេៗ

ដានី:	ខ្ចាត់ខ្ចាយដែលយួនវ៉ៃហ្នឹង?

សារ៉ាំង:	វ៉ៃល្បើកល្បាយរត់ៗ

ដានី:	វ៉ៃល្បើកល្បាយ ហើយយ៉ាងម៉េចយើងរត់ទៅណា មកខាងណា?

សារ៉ាំង:	វ៉ៃរត់ចូលទៅដីថៃ ហើយថៃដឹកពួកខ្ញុំយកមកដាក់នេះ មកនៅច្រកនេះ ជាំស្វាៗ

ដានី:	លោកពូអត់ចាំឆ្នាំទេដែលគេវ៉ៃល្បើកល្បាយ?

សារ៉ាំង:	អត់ទេ ខ្ញុំអត់ចាំឆ្នាំទេ មិនដឹងជាឆ្នាំប៉ុន្មានអីប៉ុន្មានទេ វាខ្វង់ប៉ែតៗ

ដានី:	ទៅនៅបានប្រហែលប៉ុន្មានឆ្នាំ ទៅនៅទន្លេល្ពៅហើយចូលថៃហើយចេញមកនេះ? ព្រោះ ៨១ យើងទៅ?

សារ៉ាំង:	នៅយូរដែរ ប៉ុន្មានឆ្នាំ ខ្ញុំនៅតាំងពីនៅលីវហើយបានប្រពន្ធ បានកូនមួយ ខ្ញុំមានកូនមួយៗ

ដានី:	កូនអាយុប៉ុន្មានដែលលោកពូមកនៅជាំស្វា?

សារ៉ាំង:	កូនមួយអាយុ៥-៦ខែៗ

ដានី:	ហ្នឹងកូនលោកពូកើតឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មាន?

សារ៉ាំង:	មួយពាន់ប្រាំបួនរយប៉ែត មិនដឹងប៉ែតប៉ុន្មានទេៗ

ដានី:	ឆ្នាំអីគេ?

សារ៉ាំង:	ឆ្នាំជូតៗ

ដានី:	ឆ្នាំខាល៨៦, ឆ្នាំឆ្លូវ៨៥ អាច៨៤-៨៥?

សារ៉ាំង:	បាទ! ៨៤-៨៥ហ្នឹងឯងៗ

ដានី:	អាច៨៤-៨៥ដែលគេវ៉ៃខ្ចាត់ខ្ចាយហើយយើងរត់មក រត់មកនៅខាង?

សារ៉ាំង:	រត់យើងរត់ឆ្លងភ្នំ ឡើងចុះភ្នំឆ្លងទៅដីថៃ គេចរត់ក្រោយ ហើយបានគេដឹកជនភៀសខ្លួន ដឹកយកមកនៅអូរត្រាវ មកនៅជាំស្វា គេហៅជាំស្វាៗ

ដានី:	នៅអូរត្រាវមុន ហើយបានត្រឡប់មកជាំស្វាក្រោយ?

សារ៉ាំង:	បាទ! នៅអូរត្រាវមុនហើយបានមកជាំស្វាៗ

ដានី:	អូរត្រាវ, ជាំស្វាហ្នឹងទឹកដីថៃ?

សារ៉ំង: ទឹកដីថៃ ។

ដានី: ឈ្មោះហ្នឹងឈ្មោះរបស់ថៃទេ?

សារ៉ំង: មិនដឹងដល់ហ្នឹងគេហៅអីចឹង ក៏ហៅតគ្នា ។

ដានី: ជាំស្វា, អូរត្រាវហ្នឹងជំរំ?

សារ៉ំង: ជំរំអូរត្រាវ ។

ដានី: បើជាំស្វាអត់ទេ?

សារ៉ំង: ជាំស្វាអត់ទេ អត់មានជំរំ តែកាកបាទក្រហមគ្រប់គ្រង ហ្នឹងដល់នៅអូរត្រាវយូរទៅគេដក ពួកខ្ញុំមកនៅជាំស្វានេះ ដកចេញពីជំរំហើយបានជំរំហ្នឹងគេនៅ ។

ដានី: យើងមកនៅអូរត្រាវ, ជាំស្វា អ្នកដែលធ្លាប់មកនៅខាងទន្លេល្ពៅមកនៅហ្នឹងជុំគ្នា ឬបែក សាចគ្នាមកនៅចូលជាមួយគេ?

សារ៉ំង: បែកទៀត កាលហ្នឹងអ្នកនៅ៨០១ ដែលនៅទន្លេល្ពៅ ជួនកាលគេនៅជាប់អូរត្រាវជាមួយ UNទៅ ហើយខ្ញុំមកតាមអង្គភាពដែលគេបំបែកមកអង្គភាពនៅជាំស្វា អ្នកខ្លះនៅជាមួយ បារាំងជំរំហ្នឹងទៅ ។

ដានី: តែយើងអត់មានចូលជាមួយក្រុមផ្សេងទេ? ក្រុមផ្សេងបានន័យថាក្រុមយើងនៅខាង ទន្លេល្ពៅ អ្នកនៅជាមួយខាងតាម៉ុក យើងនៅចូលគ្នា ឬអត់ទេ យើងដាច់ក្រុមយើងដាច់ៗ ពីគ្នា?

សារ៉ំង: អាហ្នឹងគេដាក់ទៅតាមមុខសញ្ញារបស់កងពល ដាក់កងពលៗ មកនៅជាំស្វាមានប៉ុន្មាន ដូច ច្របូកច្របល់គ្នា ខ្ញុំមិនចាំទេលោកគ្រូ ។

ដានី: កងពល៨០១មួយ?

សារ៉ំង: ហ្នឹងដឹងតែកងពលខ្លួនឯងនៅហ្នឹង៨០១ ហើយ៩១២ មិនច្បាស់ទេ ។

ដានី: តែច្រើនដែលនៅជាំស្វា?

សារ៉ំង: បាទ នៅច្រើនកន្លែង ។

ដានី: ជាំស្វា, ជប់រុន ហ្នឹង?

សារ៉ំង: ជប់រុន នៅនេះ តែយើងចុះទៅដីថៃគេហៅជាំស្វាហ្នឹងដីវាលចំការ ដីចំការដំឡូងថៃ គេឲ្យ នៅហ្នឹង យើងធ្វើខ្ទមនៅតាមហ្នឹង តាមអង្គភាព ។

ដានី: នៅខាងទន្លេល្ពៅគេហៅ១០០១?

សារ៉ំង: ទន្លេល្ពៅ១០០១ ។

ដានី: មកអូរត្រាវ មកជាំស្វានៅ១០០១ដដែល ឬអត់ទេ?

សាំង: ទេហ្នឹងលែងហៅ១០០១ហើយ មិនដឹងមកស្អីវិញហ្នឹងហៅជាំស្វាអីចឹងទៅ ។

ដានី: លោកពូមកនៅអូរគ្រាវ, ជាំស្វាហ្នឹងបានយូរទេ?

សាំង: មិនយូរទេ មិនដឹងប៉ុន្មានឆ្នាំទេ មិនដល់មួយឆ្នាំទេ ដល់មកនៅហ្នឹងវាត្រូវគេឲ្យមកនៅដីខ្មែរ ដល់៩១ចុះមកនៅដី មើលទីតាំងនៅនេះ ។

ដានី: ចាំមើលយួនគេដកទៅស្រុកវិញឆ្នាំ១៩៨៩ អីចឹងក្រោយមកខាងតាម៉ុក គេវៃបានខាងអន្លង់វែង តាម៉ុក គាត់ឈូសផ្លូវចុះមក ពីជាំចុះមកក្រោម គាត់ធ្វើផ្លូវចុះមក កាលហ្នឹងខាងលោកពូចាប់ផ្ដើមចុះមកពេលហ្នឹងដែរ ឬក៏ចុះមកមុនហ្នឹង ឬក៏ក្រោយហ្នឹង?

សាំង: កាលដែលចុះមកស្រករៗគ្នាហ្នឹងឯង មិនមានអ្នកណាមុន អ្នកណាក្រោយទេ ត្រូវចុះមកកាលហ្នឹងត្រូវមានផែនការមកនៅលើទឹកដីខ្មែរ មកបោះភូមិដ្ឋាននៅហ្នឹង ។

ដានី: លោកពូចុះមកមុនដំបូងចុះមកខាងត្រពាំងប្រាសាទ ឬចុះមកខាងអន្លង់វែង ។

សាំង: ខ្ញុំចុះមកត្រង់ហ្នឹង ។

ដានី: ចុះមកចំហ្នឹង?

សាំង: បាទ! ចុះមកនៅហ្នឹង នៅទឹកដីហ្នឹងតែម្ដង តាំងពីចុះមកហ្នឹង មានអ៊ុនតាក់មកហ្នឹងនៅហ្នឹងតែម្ដង ។

ដានី: ឆ្ងាយពីតាម៉ុក ដែរ?

សាំង: តាម៉ុក គាត់នៅអន្លង់វែង យើងនៅដាច់ដោយដុំៗ ហើយបានមកនៅធ្វើផ្លូវ ផ្លូវយើងឈូសពីអន្លង់វែងជាប់គ្នាមក ។

ដានី: ហ្នឹងមិនមែនផ្លូវបារាំងចាស់ទេ?

សាំង: មិនមែនទេ ផ្លូវបារាំងមានផ្លូវបារាំងនោះ តែគេធ្វើកាត់ៗចំខ្វះ ខុសខ្វះ ។

ដានី: អីចឹងលោកពូចុះមកដំបូងមកនៅកន្លែងផ្ទះលោកពូតែម្ដង ឬអត់ទេ?

សាំង: ដីខ្ញុំនៅត្រង់នោះ ខាងនោះ ។

ដានី: នៅបានប៉ុន្មានហើយយ៉ាងម៉េចទៀត?

សាំង: មកនៅនេះ នៅបានប៉ុន្មានឆ្នាំទេ ហើយដល់ទៅរដ្ឋាភិបាលវៃទៅ នៅនេះកំលាំងកងទ័ពអត់មានទេក្រោយ គេជម្លៀសចេញពីហ្នឹងទៅនៅម៉ុំអូរស្មាយ ទៅនៅហ្នឹង តំបន់នេះកងទ័ពរដ្ឋាភិបាលនៅហ្នឹងទៅ យើងចេះតែធ្វើវៃឈ្លបនាយអាយៗ ទទួលមានការផ្ដាច់ខ្លួនរបស់ ជាកែវ របស់ដុំ ជាតិ ក៏បានគេមកវៃយកនៅនេះវិញ ។

ដានី: ដំបូងនៅអូរស្មាយទេ?

សាំង: អូរស្មាយ ។

ដានី: ដីបូងចុះមកនៅដីលោកពូ?

សាំង: ដីហ្នឹង ដីនៅទាំងអស់គ្នា កន្លែងមន្ទីរ ។

ដានី: ពេលណាទៅនៅអូរស្វាយ?

សាំង: ពេលដែលទាហានរដ្ឋាភិបាលវ៉ៃឈ្នះយើងគេចចេញទៅនោះ ។

ដានី: គេចទៅខាងអូរស្វាយ?

សាំង: គេមិនបានមកវ៉ៃក្តុងក្តាំងទេ គ្រាន់តែថាដក ដឹងតែសភាពការណ៍កំលាំងគេឡើងមកវ៉ៃមិនស្រួលដកកំលាំងទៅនៅនោះ ទុកឲ្យឈ្លបនៅនេះ កំលាំងតូចតាច ហើយខ្ញុំមិនបានមកនៅតែជាមួយមីង ដល់ទៅទាហានរដ្ឋាភិបាលមកកាន់កាប់នៅហ្នឹង ធ្វើផ្ទះបានធំៗដែរ ដល់ទៅគេមករុះផ្ទះអស់ ។

ដានី: ខាងទាហានមករុះ?

សាំង: បាទ! រុះអស់ ។

ដានី: ហើយទៅនៅអូរស្វាយហ្នឹងរហូតដល់ខាង តាជុំ ជាតិ, តាជា កែវ ផ្តាច់ខ្លួនចូលរដ្ឋាភិបាល បានត្រឡប់មកនេះវិញ?

សាំង: បាទ! ត្រឡប់មក ។

ដានី: លោកពូទាក់ទងពីបញ្ហាមានទំនាស់ផ្ទៃក្នុង ក្នុងក្រុមខ្មែរក្រហមខ្លួនឯង រវាងខាងតាម៉ុក យ៉ាងម៉េចដែរបើតាមលោកពូដឹង?

សាំង: ខ្ញុំមិនដឹងសាច់រឿង មិនដឹងជាយ៉ាងម៉េច ស្រាប់តែឃើញអីចឹង ហើយខ្ញុំមនុស្សនៅក្រោយមានដឹងថាសភាពការណ៍យ៉ាងណាៗអត់ គិតតែពីរឿងគេឲ្យបង្ហាត់ក្មេង បង្ហាត់តែកូនក្មេង

ដានី: លោកពូបង្ហាត់ក្មេងពីឆ្នាំណាមក?

សាំង: ខ្ញុំបង្ហាត់ក្មេងតាំងពីនៅនេះ ។

ដានី: តាំងពីចុះមក?

សាំង: ចុះមកក្មេងៗដែលកើតមកត្រូវដល់អាយុរៀនហ្នឹងអត់មានគ្រូ គេឲ្យខ្ញុំនៅបង្ហាត់ក្មេង ជាកែវ គាត់ឲ្យបង្ហាត់ក្មេងនៅហ្នឹង ។

ដានី: មានសាលាដែលអត់?

សាំង: ធ្វើសាលាហើយ នេះនៅទីងសាលាចាស់ គ្រាន់តែធ្វើសង់សាលាប្រក់សង្កសីធ្វើសាលា ខ្ញុំបង្រៀននៅហ្នឹង ។

ដានី: បង្រៀនបានប៉ុន្មានឆ្នាំ?

សាំង: បង្រៀនមួយថ្ងៃកាត់ មួយថ្ងៃកោររកឆ្នាំមិនឃើញទេ ។

ដានី៖ បានយូរគ្រាន់ដែរ?

សាំង៖ បានយូររហូតដល់គេដេញវ៉ៃទៅនោះ ។

ដានី៖ មានគ្រូប៉ុន្មាននាក់ទៅបង្រៀន?

សាំង៖ គ្រូតាមអង្គភាព គ្រូមាន៤-៥នាក់ ។

ដានី៖ មានគ្រូ៤-៥នាក់?

សាំង៖ បាទ! គ្រូរាល់ថ្ងៃគាត់អនុការិយាល័យអប់រំស្រុក រាល់ថ្ងៃគាត់អាគ្រែតហើយតាមមើលគាត់ពិការ ។

ដានី៖ បង្រៀនពេលហ្នឹងយើងមានសៀវភៅ?

សាំង៖ មាន សៀវភៅរបស់ខ្មែរក្រហម គេបោះពុម្ពសៀវភៅឲ្យបង្រៀន មានសៀវភៅបង្រៀនត្រឹមត្រូវ ។

ដានី៖ លោកពូមាននៅសល់សៀវភៅហ្នឹងដែលអត់?

សាំង៖ អត់ បើរត់ច្រើនកន្លែងអីចឹងក្រវ៉ាត់ចោលអស់ ។

ដានី៖ ចុះខោអាវកាលពីជំនាន់លោកពូស្លៀកពាក់អីកាលហ្នឹង នៅសល់ខ្លះ?

សាំង៖ ខោអាវកងទ័ពហ្នឹង ខោអាវចិន ។

ដានី៖ ខោអាវចិននៅផ្ទះលោកពូមាននៅសល់?

សាំង៖ អត់ទេ ។

ដានី៖ មួកអី?

សាំង៖ មួកក៏គ្មាន ។

ដានី៖ ឥឡូវអស់មានតែមួង?

សាំង៖ បាទ! អស់ ។

ដានី៖ បាឡូអី?

សាំង៖ អត់ទេ ខ្ទិចខ្ទីអត់មានសល់គេរ៉ឺដំណែលចាស់ ។

ដានី៖ ឆ្នាំង ចាន អី?

សាំង៖ អត់ នៅគ្រប់ឆ្នាំងចិនមួយ ដាក់ឲ្យឆ្កែ ។

ដានី៖ លោកពូយើងបង្រៀនក្មេង បង្រៀនយ៉ាងម៉េច សៀវភៅគេបោះហ្នឹងបោះជាភាសាខ្មែរខាងខ្មែរក្រហមគេបោះខ្លួនឯង ឬយើងទៅឲ្យខាង?

សាំង៖ អត់ដឹង គេឲ្យមកសៀវភៅសំរាប់បង្រៀនអីចឹង ។

ដានី៖ ខាងណាគេឲ្យមក?

សាំង៖ តាមមេៗគាត់ឲ្យបង្រៀន មេកង១ ។

ដានី៖ ហើយបង្រៀនហ្នឹងកូនក្មេងគេឲ្យបង្រៀនពីថ្នាក់ណាដល់ថ្នាក់ណាទៅបានឈប់ ឬយ៉ាំងម៉េចទៅ?

សាំង៖ បង្រៀនបើយើងថាមានទី១-៥ ។

ដានី៖ ដល់ថ្នាក់ទី៥?

សាំង៖ បាទ! លោកគ្រូថ្នាក់ការិយាល័យគាត់រៀនដល់ថ្នាក់ទី៥ គាត់បង្រៀនបាន កូនសិស្សជំនាន់នោះរហូតដល់មានធ្វើគ្រូរាល់ថ្ងៃ ។

ដានី៖ អីចឹង?

សាំង៖ ឥឡូវមានធ្វើនាយក កូនសិស្សហ្នឹង ។

ដានី៖ គាត់រៀនតទៀតបន្ទាប់ពីសមាហរណកម្មហើយ?

សាំង៖ បាទ! ក្រោយពីសមាហរណកម្មមកគាត់រៀនត ។

ដានី៖ ហើយពេលដែលបង្រៀនយើងមានប្រជុំ ខាងលើថាត្រូវតែបង្រៀនកូនសិស្ស បង្រៀនពីអីខ្លះ ហើយបង្រៀនដល់ប៉ុណ្ណា ចូលរៀនពីអាយុប៉ុន្មាន?

សាំង៖ អត់ទេ អត់មានអីចឹងទេ ធ្វើម៉េចឲ្យតែក្មេងបានចេះអក្សរ ឲ្យតែរៀនពីអក្សរ អត់មានរៀនពីនយោបាយ អត់មានទេ រៀនអក្សរសុទ្ធៗ លេខនព្វន្តហ្នឹង ។

ដានី៖ ក្មេងចង់មករៀនក៏បាន មិនចង់ក៏បាន?

សាំង៖ បាទ! មិនមានកំរិតក្រិតក្រម ព្រោះសភាពការណ៍ពេលនោះវាមិនមែនសន្តិភាព ជួនកាលរៀនៗទៅសភាពការណ៍ចេះ សភាពការណ៍ចុះខានរៀនទៅ មិនប្រក្រតីទេ ។

ដានី៖ ហើយលោកពូដូចថាកាលជំនាន់គេបែកបាក់ផ្ទៃក្នុង ខាងនេះអត់មានប៉ះពាល់គ្នាទេ ដូចខាងកងទ័ពគេមានបែងចែកជាក្រុម ខាងអន្លង់វែង ខាងត្រពាំងប្រាសាទ?

សាំង៖ ខាងហ្នឹងគេមានបែងចែក តាម៉ុក គាត់មួយប៉ែកហ្នឹង ដែលពួកផ្តាច់ខ្លួនមកខាងនេះ នៅតាម៉ុក នៅមួយផ្នែកនៅនោះអន្លង់វែង មានការប្រទង់ប្រទាញគ្នាទំរាំបានប្រហែលជាចូល ៩៩ទំរាំបានសមាហរណកម្ម ។

ដានី៖ បើតាមទស្សនៈរបស់លោកពូ និយាយពីរឿងបែកបាក់គ្នាហ្នឹងបើមូលហេតុសំខាន់មកពីស្អីទៅ?

សាំង៖ ខ្ញុំមិនដឹងទេ ខ្ញុំមិនដឹងពីមូលហេតុអី អត់ដឹងទេ ។

ដានី៖ អត់ដឹងទេ?

សាំង៖ បាទ!

ដានី: ដល់ថ្នាក់ក្រោយមកគាត់យកមេៗមួយចំនួនយកទៅសម្លាប់?

សាំង: យក ពេលដែលបែកបាក់គ្នាហើយ គាត់យកដូចជាតា០៥, ០៦ ទៅឃុំឃាំង ហើយពួកខ្ញុំដែលនៅខាងតា០៥ ទៅជាមានទិន្នាការនយោបាយ ទៅមានទិន្នាការថាខាងនេះខាងនោះ ប៉ុន្តែគេមិនបានធ្វើបាបទេ គ្រាន់តែគេចាត់ទុកអីចឹង ។

ដានី: គេចាត់ទុកថាយើងនៅខាងបក្សពួកខាងនេះ?

សាំង: នៅខាង០៥ ។

ដានី: គេមិនធ្វើបាបអីយើងតែគេបែងចែក?

សាំង: បាទ! គេបែងចែក ។

ដានី: គេថាយើងទិន្នាការទៅខាងនោះ?

សាំង: បាទ!

ដានី: ពូគិតម៉េចទៅ?

សាំង: ខ្ញុំអត់បានគិតអីស៊ីជំរៅយ៉ាងណា នៅមួយពេលហ្នឹងគិតតែពីរឿងចិញ្ចឹមជីវិតតែម្តង មានការព្រួយបារម្ភដែរបាក់បែកគ្នាអីចឹងមិនដឹងណាណី ពេលនោះពួកបងជុំ គាត់ទៅ មុនពួកគាត់ផ្តាច់ខ្លួនគេយកពួកគាត់ទៅនៅកន្លែង ដូចថាកន្លែងអប់រំអីចឹង ដល់គាត់ត្រូវផ្តាច់ខ្លួនយើងអត់ដឹងថាគាត់ទៅហ្នឹងទេ មុននឹងទៅហ្នឹង បងមួយឈ្មោះបងសយ គាត់យកគោយករទេះមកលក់ឲ្យខ្ញុំ ។

ដានី: សារី សយ?

សាំង: បាទ! សារី សយ ហ្នឹងៗ គាត់យកគោ យករទេះមកលក់ឲ្យខ្ញុំ១ម៉ឺនបាត ខ្ញុំក៏យក គាត់លក់ហ្នឹងមិនមែនថាគាត់ទៅនោះឯណា ថាគេយកគាត់ទៅកន្លែង១៩ កាលហ្នឹងបែកចែកកន្លែង១៩ កន្លែងតាម៉ុក ខ្ញុំក៏អាណិតខ្ញុំយកហើយអីចឹង យកគោ យករទេះគាត់ ស្រាប់តែគាត់ទៅនោះបាត់ៗ ខ្ញុំហ្នឹងទៅជាគេតាមដានយកគោខ្ញុំងទិញបេះបុះ គេតាមដានដែរទទួលគេនោះគេមកវិញទាន់ទៅ មកនេះមក ។

ដានី: ដូចថាគេទៅបាត់គេតាមដានយើង?

សាំង: បាទ! គេតាម ។

ដានី: ក្រែងលោយើងមានទាក់ទងគ្នា?

សាំង: គេតាម មានទាក់ទង ។

ដានី: គិតទៅវាច្របូកច្របល់ដែរ?

សាំង: ច្របូកច្របល់ ។

ដានី: លោកពូយើងធ្លាប់រស់នៅ ឆ្លងកាត់ច្រើនដែរ និយាយទៅបទពិសោធន៍លោកពូតាំងពី៧៥-៧៦-៧៨យើងទៅព្រៃដែនហើយរត់មក ជីវិតរស់នៅយ៉ាងម៉េចដែលលោកពូ បើយើងគិតមក ឆ្លងកាត់មក?

សាំង: ជីវិតរស់នៅដែលខ្ញុំដឹងក្ដីមកដូចជាមិនដែលបានជួបស្រួល ជួបតែអីចឹងតែម្ដងលំបាក ។

ដានី: ដូចថាកាលដែលរស់នៅពី៧៩មកការតស៊ូតាមព្រៃដែនរហូតមកដល់សមាហរណកម្ម ជីវិតពេលហ្នឹងខុសប្លែកពីជីវិតដែលយើងសមាហរណកម្មហើយមកដល់ឥឡូវ ខុសគ្នាយ៉ាងម៉េចខ្លះបើយើងប្រៀបធៀបមក?

សាំង: និយាយមិនខុសម៉េច វាខុសគ្នាឆ្ងាយ ឥឡូវនេះយើងដឹងថាយើងមានសន្តិភាពរស់ដោយស្រួល ពីមុនមកអត់មានអីចឹងណា៎ ។

ដានី: ពីមុនមកយ៉ាងម៉េចខ្លះ?

សាំង: ពីមុនមកនៅក្នុងព្រៃ ចាប់ចេញពី យើងថាចាប់ផ្ដើមពី៧៩ទៅចុះ ៧៩នៅនឹងព្រៃ រហូតដល់៩៨ ។ ៧៩-៩៨សមាហរណកម្មហើយបានធូរខ្លួន មានការលំបាក ។

ដានី: លោកពូរៀបការតាំងពីឆ្នាំណា?

សាំង: ឆ្នាំ៨២ ប្រហែលជា៨២ ។

ដានី: លោកពូទៅដល់ទន្លេល្អៅ៨១ ។

សាំង: ៨២ ។

ដានី: រៀបការតាំងពីឆ្នាំ៨២?

សាំង: មិនជារៀបការ កាលនោះគ្រាន់តែផ្គុំៗ ផ្សំៗហ្នឹងមេ ។

ដានី: គាត់នៅអង្គភាពជាមួយលោកពូដែរ?

សាំង: បាទ! គាត់នៅខាងនារីៗ ។

ដានី: ទាក់ទងពីជីវភាពវិញកាលសម័យតស៊ូយើងមានរបប ដល់ក្រោយយើងសមាហរណកម្មយើងចាប់ផ្ដើមរស់នៅដោយខ្លួនឯង រកស៊ីធ្វើការខ្លួនឯង ខុសគ្នាម៉េចដែរ?

សាំង: វាខុសគ្នាត្រង់ថាមានសេរីភាពរកស៊ីខ្លួនឯងបានមានបាន ។

ដានី: បើយើងរកស៊ីខ្លួនឯង យើងអាចមានសេរីភាពរកស៊ីមានបាន?

សាំង: បាទ!

ដានី: ពីមុនមក?

សាំង: ពីមុនមកនៅក្នុងរបបនោះយើងមានបើករបបហូប តែក្រោយមកយើងមកនៅនេះគ្មានបើករបបទេ គឺអ្នកដែលនៅក្រោយធ្វើស្រែខ្លួនឯង ហូបខ្លួនឯង ប្រពន្ធៗកង់ទ័ពដែលគេទៅមុខ

គេមានរបបបើកខ្លះ ធ្វើស្រែខ្លួនឯង ហើយយើងដែលនៅក្រោយយើងជួយគេធ្វើឲ្យបាន ស៊ីធ្វើម៉េចកុំឲ្យដាច់ពោះ ។

ដានី: គេអត់មានចែកយើងទៀតទេ?

សាំង: បាទ! អត់មានទេ គ្មានស្អីចែកទៀតវាអស់ហើយ ។

ដានី: គេផ្តាច់ជំនួយ?

សាំង: បាទ!

ដានី: ហ្នឹងពេលដែលយើងចុះមកនៅខាងក្រោម ពីឆ្នាំ៩១មកយើងមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស៩១មក ខាងចិនគេឈប់ផ្តល់ជំនួយឲ្យ ។

សាំង: កាលដែលយើងមកនៅជិបូងឃើញមាន នៅមាន ឃើញដឹកអង្ករមកបើកដែរ ដឹកពីអន្លង់វែងមក ក្រោយមកដូចអស់អត់តែម្តង ។

ដានី: យើងរស់ខ្លួនឯង?

សាំង: ប្រពន្ធៗនៅក្រោយធ្វើស្រែហូបខ្លួនឯង ហើយខ្ញុំដែលនៅក្រោយហ្នឹងធ្វើខ្លួនឯងផង ជួយប្រពន្ធគេផង មើលកូនគេផង បង្រៀនផង វាយាំប់ដែរ បង្រៀនកូនគេផង ហើយឆ្លៀតទៅធ្វើស្រែ ធ្វើចំការខ្លួនឯងផង ហើយជួយគេផងធ្វើម៉េចកុំឲ្យតែគេមានការលំបាក កុំឲ្យគេអួសទាញកំលាំងមកពីមុខ ខ្លួនឯងចូលរួមចំណែកអីចឹង ។

ដានី: មួយទៀតបើយើងទាក់ទងពីមុនដែលយើងចុះមកយើងនៅលើភ្នំ អត់លំបាកទេ?

សាំង: អត់លំបាកទេ ខោអាវស្លៀកពាក់ ហូបចុកអី ។

ដានី: ថ្នាំសង្កូវពេទ្យអត់ខ្វះទេ?

សាំង: អាហ្នឹងវាមិនសំបូរដូចយើងមានខ្លួនរបស់យើងទេ របបបើក ប៉ុន្តែមិនដាច់បាយ ដាច់ទឹកអត់មានទេ ដល់ខែបើកៗ គ្រាន់តែមានអី មានតែអង្ករ ម្ហូប កំប៉ុងក្រៀមក្រោះ អំបិល

ដានី: លោកពូមានប្រសាសន៍អីចឹងខ្ញុំចាប់អារម្មណ៍មួយ អ្នកខ្លះដូចលោកពូមានប្រសាសន៍ម៉ិញយើងមានសេរីភាពយើងរកស៊ី យើងមានបាន តែមួយផ្នែកទៀតក្រោយពីសមាហរណកម្មទៅគាត់ដូចថារកស៊ីមិនសមប្រកប ឬគាត់មិនសូវប្រឹងប្រែង ជីវភាពគាត់អត់សូវបានល្អគាត់វាងក្រខ្សត់ គាត់គិតថាកាលពីមុនមានរបបហូបចុកទៅមិនបាច់គិតអីច្រើន ដឹងតែយើងធ្វើការទៅមាន ឥឡូវត្រូវការរកស៊ី បើមិនរកទេអត់មានអី ហ្នឹងយ៉ាងម៉េចទៅបើតាមយោបល់លោកពូ?

សាំង: គំនិតនេះមិនល្អទេ មនុស្សត្រូវតែមានសេរីភាពខ្លួនឯង បើគេឲ្យមានសេរីភាពរកស៊ីចិញ្ចឹមជីវិតដោយខ្លួន រកមិនបានចាំទៅពឹងរបបបើក មិនស្រួលទេ គំនិតមិនល្អ ខ្ញុំមិនគិតថាអីចឹង

ទេ នៅក្នុងការគេឲ្យស៊ីថ្ងៃណាគេឲ្យស៊ី ស៊ីទៅ អត់ៗម៉េច ស្រួលអីៗ ចុះបើយើងរកខ្លួនយើង ខ្លួនទីពឹងខ្លួន គ្មានស្អីល្អខ្លួនទីពឹងខ្លួនៗ

ដានីៈ លោកពូដូចថាភូមិ-ឃុំយើងនេះចាប់ផ្ដើមបង្កើត ចាប់ផ្ដើមកសាងពីឆ្នាំណាមក?

សាំងៈ ដែលបង្កើតនេះក្រោយសមាហរណកម្មហ្នឹងមានរៀបចំបង្កើតជាភូមិ ជាឃុំ ក្រោយសមាហរណកម្មមកៗ

ដានីៈ ដូចជាឈ្មោះអី ខ្ញុំសួរនាំ មានដាក់ឈ្មោះភូមិទួលប្រាសាទ ភូមិសែន សុខ, ភូមិទំនប់ដាច់, ភូមិទួលពន្រ, ភូមិជ័យនិវត្តន៍, ភូមិទួលចារ ហ្នឹងសំរេចបង្កើតមកដាក់ឈ្មោះក្រោយសមាហរណកម្មមក ហើយ ឬឈ្មោះហ្នឹងគេមានពីដើមមក?

សាំងៈ អត់ទេ ក្រោយសមាហរណកម្មដែលបង្កើតមានភូមិ-ឃុំ បានបង្កើតឈ្មោះ ប៉ុន្តែឈ្មោះនេះមួយជ័យនិវត្តនេះគឺ០៥ គាត់ដាក់ពេលចុះមកតំបន់នេះគេហៅថាជ័យនិវត្តន៍ មានន័យថាវាវិវត្តន៍ពីនោះមកនៅនេះ ពីភ្នំមុន មានន័យថាអីចឹង គាត់ដាក់ហ្នឹង ជ័យនិវត្តន៍ហ្នឹងកន្លែងហ្នឹង ដល់ទៅកន្លែងភូមិហ្នឹងខ្ញុំដាក់ភូមិហ្នឹងមួយ ឲ្យជាប់និវត្តន៍ៗ

ដានីៈ នឹកឃើញដល់គាត់?

សាំងៈ បាទ!

ដានីៈ ដូចថាកាលហ្នឹងកំលាំង ទាក់ទងកំលាំងវិញក្នុងមួយឃុំហ្នឹងកំលាំងប៉ុន្មាន ជាអង្គភាពអីហើយយើងចែកឃុំ ហើយភូមិៗ យើងបានកំលាំងយ៉ាងម៉េចខ្លះ?

សាំងៈ វាចេះ ដូចភូមិទួលប្រាសាទហ្នឹងមានប្រាសាទឥដ្ឋនៅដល់សព្វថ្ងៃទេ ហ្នឹងមួយអង្គភាព មួយវរៈគេនៅហ្នឹងៗ

ដានីៈ មួយវរសេនាតូច?

សាំងៈ មួយវរសេនាធំ មានគេនៅហ្នឹង ក៏គេដាក់ហ្នឹងហៅថា៨៩៧ទេៗ

ដានីៈ វរសេនាធំ៨៩?

សាំងៈ ក្រោយមកគេដាក់ភូមិទួលប្រាសាទ ហើយខិតពីហ្នឹងតិចមកមេមួយទៀត វរសេនាធំមួយទៀតភូមិសែនសុខ មេហ្នឹងមេវរសេនាធំថាឲ្យដាក់ភូមិសែនសុខ ដាក់តាមគេទៅៗ

ដានីៈ ហ្នឹងវរសេនាធំលេខប៉ុន្មាន?

សាំងៈ ៨៦ ៗ

ដានីៈ ពីណាគេអ្នកប្រាប់ឲ្យដាក់? មេហ្នឹងឈ្មោះអីគេ?

សាំងៈ ពូសុន នាមត្រកូលគាត់ស្អីទេៗ

ដានីៈ ឥឡូវគាត់នៅណា?

សាំង៖ នៅបាធលុធ ។

ដានី៖ ទៅនៅបាធលុធវិញ?

សាំង៖ បាទ! គាត់មេទាហាន ។

ដានី៖ អីចឹងមួយភូមិមួយវរសេនាធំតែម្តង?

សាំង៖ បាទ! មួយភូមិនោះវរសេនាធំ ភូមិនេះមួយវរសេនាធំ ត្រង់នេះកន្លែងមន្ទីររបស់០៥ នៅនេះ កន្លែងខ្ញុំដើរ ។

ដានី៖ ផ្ទះលោកពូនៅក្នុងភូមិអី?

សាំង៖ ទួលពង្រ ។

ដានី៖ ផ្ទះលោកពូសព្វថ្ងៃនេះរស់នៅក្នុងភូមិទួលពង្រ ឃុំទំនប់ដាច់?

សាំង៖ ស្រុកត្រពាំងប្រាសាទ ។

ដានី៖ អីចឹងភូមិនេះ ភូមិទួលពង្រកន្លែងផ្ទះលោកពូនេះមន្ទីររបស់០៥ ។

សាំង៖ កន្លែងស្រះដីកហ្នឹង កាលយើងមកនៅដំបូងមានឆប័ររបស់ថៃនៅ ។

ដានី៖ មួយមន្ទីរគ្នាច្រើនដែរ?

សាំង៖ បាទ! មួយមន្ទីរគ្នាច្រើនណាស់ ។

ដានី៖ អីចឹងអ្នកនៅទួលពង្រភាគច្រើននៅមន្ទីរ?

សាំង៖ អត់ទេ មានអ្នកពីក្រៅដែរ ឥឡូវនេះវារលាយរូបភាពអស់ហើយ អ្នកថ្មីមកនៅគគោក ។

ដានី៖ ប៉ុន្តែពីដំបូងមកក្នុងតួជាមន្ទីរ?

សាំង៖ កន្លែងនេះកន្លែងមន្ទីរ គាត់នៅត្រង់ហ្នឹង ផ្ទះគាត់នៅនោះ គាត់ចាប់ដីត្រង់នេះកន្លែងមន្ទីររបស់គាត់ នោះ៨៩ នេះ៨៦ ទៅក្រោយនោះ៨១ ។

ដានី៖ នោះភូមិអី?

សាំង៖ ខ្ញុំដាក់ថាភូមិទួលចារ ។

ដានី៖ ទួលចារ ៨១ ។ វរសេនាធំ៨១?

សាំង៖ បាទ!

ដានី៖ ប្រធានវរសេនាធំពីណាគេ?

សាំង៖ វរសេនាធំដែលនៅ ៨១មកនៅនេះពីណាគេទេ មិនដឹងពីណាគេទេគ្រប់គ្រង៨១ ។

ដានី៖ ហ្នឹងនៅទួលចារ៨១, ចាំមើល៨៩នៅខាងទួលប្រាសាទ, សែនសុខ៨៦, ទួលពង្រមន្ទីរតា០៥ ដល់ពេលទួលចារ៨១ ។

សាំង:	ជ័យនិវត្តន៍នោះមានមន្ទីររបស់ ជា កែវ នៅហ្នឹងដែរ ហើយនិងអន្តុភាព៨៥ វរសេនាធំ ៨៥ នៅជ័យនិវត្តន៍។

ដានី:	ចុះខាងទំនប់ដាច់?

សាំង:	ភូមិទំនប់ដាច់មនុស្សដែលនៅភូមិទំនប់ដាច់ខ្ញុំគិតថាឃុំទំនប់ដាច់ ភូមិទំនប់ដាច់។

ដានី:	ហ្នឹងអត់មានវរសេនាធំអីទេ?

សាំង:	មានមេវរសេនាធំ៨៤គាត់នៅ។ មេកន្ទ្រាញនៅម្ដុំហ្នឹង អ៊ុំង លាង ដីគាត់ហ្នឹង គាត់នៅហ្នឹង មេត្រង់ហ្នឹង អ៊ុំង លាង។

ដានី:	កាលហ្នឹងគាត់ជាគណៈកងពល?

សាំង:	មិនដឹងត្រង់ណា នៅអន្តុភាព៨៤ មេវរសេនាធំ៨៤ ជាសមាជិកអីហ្នឹងតាមមើល។

ដានី:	ចុះ៨២នៅណាវិញ?

សាំង:	៨២នៅនោះត្រពាំងប្រាសាទ។

ដានី:	វរសេនាធំ៨២នៅខាងត្រពាំងប្រាសាទវិញ។

សាំង:	៨២នៅ។

ដានី:	៨៣?

សាំង:	អត់មានទេ៨៣។ ៨៣ មានពីមុនដឹង ពីសម័យមុន ដល់ឥឡូវអត់មាន៨៣ទេ។

ដានី:	ចារថ្មី មានដែលអត់?

សាំង:	ទើបតែបង្កើត ប្រជាជនមកនៅៗ គេធ្វើផ្លូវហ្នឹងមួយទៅបង្កើតភូមិហ្នឹង ទៅដាក់ ឧបសម្ព័ន ចេញពីទួលចារ ដាក់ចារថ្មី។

ដានី:	៨៧, ៨៨ អត់មានទេ?

សាំង:	អត់មានទេ។

ដានី:	តែមាន៨៩។

សាំង:	បាទ! មាន៨៩។

ដានី:	អីចឹងមួយទំនប់ដាច់ហ្នឹងមួយកងពល៨០១តែម្ដង ឬមួយផ្នែករបស់កងពល៨០១ទេ?

សាំង:	៨០១។

ដានី:	ឃុំទំនប់ដាច់ហ្នឹងមួយកងពល៨០១តែម្ដង?

សាំង:	បាទ!

ដានី:	កងពល៨០១ទាំងមូលតែម្ដង?

សាំង:	បាទ!

ដានី: ចុះឃុំផ្សេងទៀត ដូចឃុំបាក់អន្លង់, ព្រះប្រឡាយ?

សាំង: ព្រះប្រឡាយ៦០២ ។

ដានី: កងពលរបស់ពីណាគេ?

សាំង: តាហឿន ។

ដានី: ៦១២ ។

សាំង: ៦១២របស់តាហឿន នៅច្រកព្រះប្រឡាយ ។

ដានី: ហ្នឹងកងពលរបស់គាត់?

សាំង: បាទ!

ដានី: ច្រកព្រះប្រឡាយខាងនោះវិញ?

សាំង: ច្រកជប់រុនហ្នឹង ច្រកប្រឡាយ ។

ដានី: បើយើងចង់ទៅខាងឃុំព្រះប្រឡាយទៅតាមផ្លូវណា?

សាំង: ឃុំព្រះប្រឡាយជាប់ខ្ញុំនេះតាមផ្លូវជាតិ តែបែកដែនដីគឺច្រកព្រះប្រឡាយគឺឃុំព្រះប្រឡាយហ្នឹងឯង ។

ដានី: អីចឹងខាងឃុំព្រះប្រឡាយ កងពល៦១២ ដល់ពេលខាងឃុំត្រពាំងប្រាសាទ?

សាំង: ៨០២ ។

ដានី: ដល់ពេលឃុំបាក់អន្លង់?

សាំង: ៨១៧ មេ៨១៧ ជុំ ជាតិ ។

ដានី: មួយបាក់អន្លង់ហ្នឹងតែម្ដង?

សាំង: បាទ!

ដានី: ដល់ខាងអូរស្មាច់?

សាំង: អូរស្មាច់មនុស្សមាន៨០១ផង អូរស្មាច់ទើបនៅក្រោយយើងសមាហរណកម្មមានបានឈ្មោះអូរស្មាច់ មាន៨០១ផង ៩១២ផង នៅហ្នឹង ដល់យើងចេញមកនៅនេះមកអ្នកខ្លះក៏គេនៅហ្នឹងទៅ នៅហ្នឹងបង្កើតឃុំមួយទៀត ។

ដានី: ឃុំផ្អាវ?

សាំង: វាពាក់ព័ន្ធនឹងឃុំផ្អាវហ្នឹងវាមនុស្សនៅថ្លូវច្រើនកងពល តាញ៉ែន ៦១៦ ។

ដានី: តាញ៉ែន ដែលគាត់ទៅខាងសៀមរាប?

សាំង: តាញ៉ែន អនុតាវិន ខ្ញុំឃើញនឹកឃើញ កាលពីនៅវ៉ៃព្រាំដែន តាញ៉ែន គាត់វរសេនាធំផងហើយអនុផង តាញ៉ែន ។

ដានី: អីចឹងមានឃុំផ្អាវ, ឃុំអូរស្វាយ, ឃុំត្រពាំងប្រាសាទ, ឃុំបាក់អន្លង់, ឃុំទំនប់ដាច់ និងឃុំព្រះប្រឡាយ ។ បើឈ្មោះដូចជា ទួលប្រាសាទ ដោយសារមានទួលប្រាសាទ ។ សែនសុខម៉េចបានដាក់ឈ្មោះសែនសុខ?

សាំង: មេគេដាក់សែនសុខក៏ហៅសែនសុខទៅ មេស៊ុន មិនដឹងមានន័យយ៉ាងម៉េច ។

ដានី: នេះហៅតាមគាត់ ចុះទួលពង្រ?

សាំង: ហ្នឹងគាត់គិតឃើញថាចេះ គាត់គិតថាវាចប់បានសេចក្តីសុខ ធម្មតាសង្គ្រាមវាលំបាកលំបិនយ៉ាប់ដល់បានឯករាជ្យដាក់សែនសុខឲ្យសុខតែម្តង មានន័យថាអីចឹងតាមមើល ។ ឯទួលពង្រនេះខ្ញុំអ្នកដាក់ទួលពង្រ ខាងកើតមានទួលមានដើមពង្រ ដាក់ទួលពង្រ មិនមានគំនិតអីថាយ៉ាងណាទេកាលនោះចេះតែដាក់ឲ្យមានឈ្មោះ ។ ដល់ពេលឥឡូវមកធ្វើនិក្ខេបបទក្នុងភូមិបានវេទនា លំបាកសរសេរនិក្ខេបបទ ។

ដានី: សរសេរជាប្រវត្តិ?

សាំង: បាទ! កាលនោះចេះតែដាក់ ។

ដានី: ទំនប់ដាច់ ដោយសារម៉េចបានយើងដាក់ទំនប់ដាច់?

សាំង: រឿងទំនប់ដាច់ឈ្មោះដែលហៅថាទំនប់ដាច់វាជាឈ្មោះពីសម័យនោះមកដែរ ដែលជាប់កងទ័ព ប្រជាជននៅលើ តែមានកងទ័ពគេធ្វើការតាមព្រំដែន ពេលដែលកាលនោះយួនអត់ទាន់រើឡើងលើភ្នំទេ យើងនៅមានធ្វើការនៅខាងក្រោមនេះ មានលើកទំនប់មួយនោះអាអូរនោះ មានកងទ័ព មាននារីដឹកជញ្ជូន ប្រវត្តិដែលហៅទំនប់ដាច់ដោយសារកងដឹកជញ្ជូនស្បៀងមកឲ្យកងទ័ពវាមិនរួចទំនប់ហ្នឹងវាដាច់ លើកទំនប់គាត់អូរធំនោះ ដល់ភ្លៀងជន់វាដាច់ឆ្លងមកមិនរួចវាដាច់ទំនប់ក៏ហៅទំនប់ដាច់ៗទៅ វាជាប់ជាទំនប់ដាច់ តាមផ្លូវក្រហមចាស់ អីចឹងក៏ដាក់ទំនប់ដាច់អីចឹង តាមហៅទំនប់ដាច់ប្រវត្តិវា ។

ដានី: ដល់ពេលដាក់ឃុំទំនប់ដាច់ ភូមិទំនប់ដាច់មួយក្នុងឃុំហ្នឹង!

សាំង: បាទ!

ដានី: ចុះឃុំទួលចារ?

សាំង: ភូមិទួលចារ ។

ដានី: ភូមិទួលចារម៉េចដែរ?

សាំង: ភូមិទួលចារកន្លែង៨១ ហ្នឹងនិយមហៅថាទួលចារ ព្រោះវាមានភូមិហ្នឹងទួលវែង ភូមិហ្នឹងស្អាតណាស់ តែក្នុងហ្នឹងវាមានដើមចារផ្កាក្រហមៗ វាសំបូរដើមហ្នឹងក៏ហៅទួលចារៗ ក៏

ឈ្មោះទួលចារ ដូចខ្ញុំនិយាយថាវាមិនបានគិតប្រវត្តិអីម៉ត់ចត់ទេ នឹកឃើញដាក់ៗឲ្យតែមាន កើត ដល់មានការសរសេរនិក្ខេបបទ ជីវប្រវត្តិរបស់ភូមិមិនដឹងស្អីៗ សរសេរមិនចង់ចេញ

**ចប់**